CDRI
Cambodia Development Resource Institute

ឯកសារសង្ខេប
គោលនយោបាយ

ឆ្នាំ២០២៤ លេខ០២

# ការពង្រឹងភាពធន់នៅជនបទដើម្បីឆ្លើយតបនឹងចំណាកស្រុកដោយសារការប្រែប្រួលអាកាសធាតុ

## សារសំខាន់ៗ

- ជនចំណាកស្រុកមានការងារធ្វើ ជាប្រចាំឆ្នាំ និងតាមរដូវកាល ដែលទំនាក់ទំនងសង្គមមានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកឱកាសការងារ ជាពិសេសសម្រាប់ស្ត្រី
- ជីវភាពរបស់គ្រួសារជនចំណាកស្រុក រងការប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ ដែលលំបាកក្នុងការព្យាករណ៍ ការខ្វះទឹកសម្រាប់ប្រើប្រាស់ និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជា កំដៅឡើងខ្លាំង រាំងស្ងួត និងទឹកជំនន់ ដែលធ្វើឱ្យផលានុផលដំណាំ និងបរិមាណត្រីធ្លាក់ចុះ។ នេះបណ្តាលឱ្យមានការបាត់បង់ចំណូល និងអស្ថិរភាពផ្នែកហិរញ្ញវត្ថុ ជាពិសេសសម្រាប់គ្រួសារដែលពឹងផ្អែកលើកសិកម្ម។
- ការធ្វើចំណាកស្រុក ត្រូវបានជំរុញដោយបញ្ហាសេដ្ឋកិច្ចរួមមាន ភាពក្រីក្រ ការខ្វះការងារ និងបំណុល។ បញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរ ដោយសារផលប៉ះពាល់ពីកត្តាអាកាសធាតុ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលបានធ្វើឱ្យផលិតផលកសិកម្មថយចុះ។
- គ្រួសារជនចំណាកស្រុកដោះស្រាយបញ្ហាទាំងនេះ តាមរយៈការចូលរួមក្នុងគម្រោងអភិវឌ្ឍ សហគមន៍ ការអនុវត្តបច្ចេកទេសកសិកម្មធន់នឹងអាកាសធាតុ និងបន្ថែមប្រភពចំណូល។ ទោះបីជាយ៉ាងណា ដើម្បីពង្រឹងសមត្ថភាពបន្សាំ ក្នុងការទប់ទល់នឹងបញ្ហាអាកាសធាតុ គ្រួសារជនចំណាកស្រុកត្រូវការបន្ថែម ដូចជា វិធានការគាំពារសង្គម ការបណ្តុះបណ្តាលបច្ចេកទេសនៅមូលដ្ឋាន និងការបញ្ចូលផែនការធន់នឹងអាកាសធាតុ ចូលទៅក្នុងការអភិវឌ្ឍថ្នាក់មូលដ្ឋាន។
- ដើម្បីបង្កើនជីវភាពថ្នាក់មូលដ្ឋាន បង្កើនសមត្ថភាពបន្សាំ និងបន្ថយការធ្វើចំណាកស្រុក ដោយសារតែការប្រែប្រួលអាកាសធាតុ ខាងក្រោមជាតម្រូវការអភិវឌ្ឍន៍ដែលចាំបាច់៖

## នៅថ្នាក់ក្រោមជាតិ

- ការបណ្តុះបណ្តាលកសិកម្ម៖
  - អនុវត្តការបណ្តុះបណ្តាលនៅថ្នាក់មូលដ្ឋាន ដោយប្រើប្រាស់ចំណេះដឹង និងធនធានក្នុងតំបន់។
  - ផ្តោតលើបច្ចេកទេសកសិកម្ម ធន់នឹងអាកាសធាតុ ដែលសមស្របសម្រាប់កសិករ និងសហគមន៍។
  - ណែនាំកសិកម្មឆ្លាតវៃ និងការអនុវត្តកសិកម្ម ដែលនាំទៅរកប្រព័ន្ធអេកូឡូស៊ីកសិកម្ម ប្រកបដោយនិរន្តរភាព ផលិតភាពខ្ពស់រយៈពេលវែង និងបង្កើតប្រាក់ចំណូលពេញមួយឆ្នាំ។
  - ធានាថា មន្ត្រីកសិកម្មឃុំផ្តល់ សេវាកម្មផ្សព្វផ្សាយ ប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនផលិតភាពកសិកម្ម។
- ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ៖
  - សាងសង់ និងថែទាំប្រព័ន្ធធារាសាស្ត្រ រួមទាំងស្ថានីយបូមទឹកដើរដោយពន្លឺព្រះអាទិត្យ នៅក្នុងឃុំ និងស្រុក ដើម្បីគាំទ្រការផលិតកសិកម្មក្នុងតំបន់។
  - ពង្រឹងសមត្ថភាពរបស់សហគមន៍ ដើម្បីគ្រប់គ្រងធនធានទឹក ដើម្បីធានានិរន្តរភាពបាន
- ការចូលរួមរបស់សហគមន៍៖
  - បង្កើនការចូលរួមរបស់សហគមន៍ នៅក្នុងការធ្វើផែនការ និងអនុវត្តគម្រោងអភិវឌ្ឍន៍។
  - បង្កើត និងពង្រឹង គណៈកម្មការនៅមូលដ្ឋាន ដើម្បីត្រួតពិនិត្យយុទ្ធសាស្ត្របន្សាំ និងធានាថា វានឹងឆ្លើយតបនឹងតម្រូវការជាក់លាក់របស់សហគមន៍។
  - បង្កើតទីផ្សារកសិកម្មមូលដ្ឋាន នៅក្នុងឃុំ ដើម្បីពង្រឹងការចូលទៅកាន់ទីផ្សារសម្រាប់ផលិតផលក្នុងស្រុក។
- ការអភិវឌ្ឍជំនាញរបស់យុវជន៖
  - លើកទឹកចិត្តយុវជន ដែលមាន/គ្មានពិការភាព ចូលរួមក្នុងកម្មវិធី បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍ

សង្ខេបគោលនយោបាយនេះរៀបរៀងដោយ ខាន់ ដូនីរ៉ា នង-មុនិន្ទ អាង-រស្មី ងិន-ច័ន្ទរិទ្ធ មជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាននៃ វិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Khan Donira, Nong Monin, Ang Raksmey, and Ngin Chanrith. 2024. *Enhancing Rural Resilience for Climate-Induced Migration Responses.* Policy Brief 2024 No. 02. Phnom Penh: CDRI.

    - ជំនាញ និងឱកាសការងារ ប្រកបដោយភាពធន់នឹងអាកាសធាតុ។
    - លើកទឹកចិត្តយុវជននៅមូលដ្ឋាន ដើម្បីចូលរួមក្នុងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សហគមន៍។
    - បង្កើតបណ្តាញយុវជន ដើម្បីចែករំលែកការអនុវត្តល្អៗ និងបណ្តុះសមត្ថភាព។

## នៅថ្នាក់ជាតិ

- ការបង្កើតគោលនយោបាយ៖
    - បញ្ចូលការធ្វើចំណាកស្រុក ដោយសារតែការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការដែលពាក់ព័ន្ធ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុបានកាន់តែប្រសើរ។
    - បង្កើតគោលនយោបាយ គាំទ្រដល់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព ដែលមានលក្ខណៈត្រូវនឹងប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងលើកទឹកចិត្តកសិករក្នុងការទទួលយក បច្ចេកទេសកសិកម្មដោយនិរន្តរភាព។
    - រួមបញ្ចូល ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការធ្វើចំណាកស្រុក ទៅក្នុងរបាយការណ៍រួមចំណែករបស់ប្រទេសកម្ពុជា ក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (NDC) និងផែនការសកម្មភាព។
- ការស្រាវជ្រាវ និងអភិវឌ្ឍន៍៖
    - លើកស្ទួយការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្មដ៏ជាក់លាក់ ដែលអាចបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងធន់នឹងអាកាសធាតុ។
    - រៀបចំផែនទី ធនធានក្នុងតំបន់ និងក្រៅតំបន់ ដើម្បីគាំទ្រគម្រោងបន្សុំា និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- ការបង្កើនសមត្ថភាព៖
    - ពង្រឹងសមត្ថភាពរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអង្គការនៅតាមសហគមន៍ ដើម្បីរៀបចំ និងអនុវត្តគម្រោងបន្សុំាដែលសមស្រប។

## ការណែនាំអនុវត្ត

- កំណត់តួនាទី និងទំនួលខុសត្រូវ របស់ស្ថាប័នរដ្ឋាភិបាលនីមួយៗ ដែលពាក់ព័ន្ធនឹងសកម្មភាពគោលនយោបាយឱ្យច្បាស់លាស់។
- ផ្តល់ផែនការអនុវត្តន៍ជាជំហានៗ រួមទាំងកាលបរិច្ឆេទ និងធនធានដែលត្រូវការ។
- រៀបចំកិច្ចសន្ទនាគោលនយោបាយ ដើម្បីពិភាក្សា និងកែលម្អ ការណែនាំទាំងនេះ ជាមួយនឹងភាគីពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## សេចក្តីផ្តើម

ការកើនឡើងភាពធ្ងន់ធ្ងរ និងញឹកញាប់នៃគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ កំពុងគំរាមកំហែងដល់ជីវភាពរស់នៅប្រជាជនជុំវិញពិភពលោក។ នៅតំបន់ងាយរងគ្រោះដោយគ្រោះមហន្តរាយទាំងនេះ រួមមានការបាត់បង់ដីធ្លី ផ្ទះសំបែង ដំណាំ និងសត្វចិញ្ចឹម អាចបង្ខំឱ្យប្រជាជនធ្វើចំណាកស្រុកដើម្បីរស់រានចិញ្ចឹមជីវិត (Mastrorillo et al. 2016)។ ទំនាក់ទំនងនេះរវាងការប្រែប្រួលអាកាសធាតុ និងចំណាកស្រុក មានទាំងក្នុងគ្រោះមហន្តរាយភ្លាមៗ និងការប្រព្រឹត្តទៅនៃការបាត់បង់បរិស្ថានបន្តិចម្តងៗ (Leighton 2009; Docherty and Giannini 2009)។

កម្ពុជា ជាពិសេសងាយរងផលប៉ះពាល់ពីបញ្ហាទាំងនេះ។ ព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសធាតុ ដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត បានប៉ះពាល់ដល់ផលិតផលកសិកម្ម និងបង្កការខូចខាតដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម (Sok et al. 2021; Chhinh et al. 2023)។ ភាពមិនប្រាកដប្រជានេះ អាចជាកត្តាមួយ ដែលជំរុញឱ្យកម្ពុជាមានអត្រានៃការធ្វើចំណាកស្រុកខ្ពស់ ទាំងក្នុងស្រុក និងក្រៅស្រុក ជាពិសេសពីជនបទទៅទីក្រុង (NIS, 2020)។ ទោះបីជាតម្រូវការទិន្នន័យជាក់លាក់នៅមានកម្រិតក៏ដោយ ការស្រាវជ្រាវបានសន្និដ្ឋានថា សម្ពាធបង្កដោយកត្តាបរិស្ថាន និងការស្វែងរកប្រភពចំណូលបន្ថែម បានជំរុញឱ្យមាននិន្នាការធ្វើចំណាកស្រុកនៅកម្ពុជា (IOM, 2009)។ ការប្រែប្រួលអាកាសធាតុក៏មានឥទ្ធិពលលើយេនឌ័រ ដែលអាចបង្កើនបន្ទុកលើស្ត្រី នៅពេលដែលរចនាសម្ព័ន្ធគ្រួសារ និងតួនាទីប្រពៃណីផ្លាស់ប្តូរ ដើម្បីឆ្លើយតបទៅនឹងការធ្វើចំណាកស្រុក (Goh, 2012)។

ការយល់ដឹងអំពី ភាពស្មុគស្មាញនៃការប្រែប្រួលអាកាសធាតុ ប៉ះពាល់ដល់ទម្រង់នៃការធ្វើចំណាកស្រុក គឺមានសារៈសំខាន់ជាពិសេស នៅក្នុងតំបន់ដែលទិន្នន័យនៅមានកម្រិត (ADB, 2012)។ ឯកសារសង្ខេបគោលនយោបាយនេះ បានសិក្សាពីទំនាក់ទំនងនេះនៅកម្ពុជា ដោយពិនិត្យមើលថាព្រឹត្តិការណ៍អាកាសធាតុកន្លងមក និងនាពេលបច្ចុប្បន្ន បានប៉ះពាល់យ៉ាងដូចម្តេចខ្លះ ទៅនឹងការធ្វើចំណាកស្រុកនៅសហគមន៍ជនបទ។ ការសិក្សានេះ ក៏ពិនិត្យមើលពីផលប៉ះពាល់ដោយផ្ទាល់នៃការប្រែប្រួលអាកាសធាតុ ទៅលើការបម្លាស់ទីផងដែរ។ គោលបំណង គឺដើម្បីលើកឡើងនូវយុទ្ធសាស្ត្រដែលសមស្រប ក្នុងការដោះស្រាយបញ្ហា សម្រាប់ប្រជាជនដែលរងផលប៉ះពាល់។

អនុសាសន៍គោលនយោបាយនេះ បានដកស្រង់ពីលទ្ធផលសំខាន់ៗនៃការស្រាវជ្រាវ ដែលបានធ្វើឡើងនៅខែមិថុនា និងខែកក្កដាឆ្នាំ២០២៣ ដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។ វិធីសាស្ត្រទាំងនេះ រួមមាន ការពិនិត្យឯកសារមានស្រាប់ ការសង្កេតតំបន់សិក្សា ការសម្ភាសជាមួយអ្នកជំនាញ និងអង្កេតតាមគ្រួសារចំនួន ២៤០ ដែលមានសមាជិកធ្វើចំណាកស្រុក នៅក្នុងឃុំទាំងបីគឺ ស្រែខ្ទុម (មណ្ឌលគិរី) ក្បាលរមាស (ស្ទឹងត្រែង) និងកញ្ជរ (ក្រចេះ)។ លទ្ធផលពីកិច្ចសន្ទនាគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានធ្វើឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ជាមួយនឹងមន្ត្រីរដ្ឋបាលខេត្តពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ក៏ត្រូវបានបញ្ចូលក្នុងឯកសារសង្ខេបគោលនយោបាយផងដែរ។

## *លក្ខណៈរបស់ជនចំណាកស្រុក*

ជាធម្មតា ជនចំណាកស្រុកភាគច្រើន ធ្វើការងារប្រចាំឆ្នាំ បន្ទាប់មកមានការធ្វើចំណាកស្រុកតាមរដូវកាល ដែលពេញនិយមក្នុងចំណោមបុរស។ ឯការធ្វើចំណាកស្រុកអចិន្ត្រៃយ៍ បង្ហាញពីនិន្នាការតែមួយ គឺពេញនិយមក្នុងចំណោមស្ត្រី។ ការងារក្រៅប្រទេស ផ្តល់ប្រាក់ចំណូលខ្ពស់ជាងការងារក្នុងស្រុក ដោយបុរសទូទៅរកបានច្រើនជាងស្ត្រី នៅគ្រប់ទីគោលដៅចំណាកស្រុក លើកលែងតែក្នុងខេត្ត។ ភាពខុសគ្នានៃសេដ្ឋកិច្ចគឺច្បាស់ ដោយបុរសចំណាកស្រុក ទូទៅរកចំណូលបានច្រើនជាងស្ត្រីដូចគ្នា លើកលែងតែក្នុងតំបន់ដែលស្ត្រីរកបានច្រើនជាងបន្តិច។ ប្រាក់ចំណូលខ្ពស់បំផុតត្រូវបានរាយការណ៍ ដោយជនចំណាកស្រុកទៅក្រៅប្រទេស ដោយបុរសរកចំណូលខ្ពស់ជាងស្ត្រី។ ការធ្វើចំណាកស្រុកទៅទីក្រុង ផ្តល់ប្រាក់ចំណូលប្រហាក់ប្រហែលសម្រាប់ក្រុមភេទទាំងពីរ ដែលប្រហាក់ប្រហែលនឹងប្រាក់ខែអប្បបរមា ២០០ ដុល្លារក្នុងមួយខែ។ ផ្ទុយទៅវិញ ការងារនៅក្នុងមូលដ្ឋាន ផ្តល់ប្រាក់ចំណូលទាបបំផុត ជាពិសេសសម្រាប់ស្ត្រី។

ទំនាក់ទំនងសង្គម មានតួនាទីសំខាន់ក្នុងការទទួលបានការងារ ដោយក្រុមភេទទាំងពីរពឹងផ្អែកខ្លាំងលើមិត្តភក្តិ អ្នកជិតខាង និងសាច់ញាតិ។ ស្ត្រីចំណាកស្រុកមានទំនោរពឹងផ្អែកលើការតភ្ជាប់សង្គមកាន់តែខ្លាំង ខណៈបុរសចូលចិត្តប្រើប្រាស់សេវាកម្មអនឡាញ និងទំនាក់ទំនងផ្ទាល់ជាមួយនិយោជក ឬក្រុមហ៊ុន។ ការប្រើប្រាស់ភ្នាក់ងារ ទាំងស្របច្បាប់ និងក្រៅច្បាប់ សម្រាប់ទទួលបានការងារ គឺមិនសូវមានញឹកញាប់ទេ ក្នុងចំណោមជនចំណាកស្រុក។

## *មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ និងផលប៉ះពាល់របស់វាទៅលើជីវភាពរស់នៅ*

ការប្រែប្រួលអាកាសធាតុ បានប៉ះពាល់យ៉ាងអាក្រក់ទៅលើប្រភពចំណូល និងជីវភាពរស់នៅរបស់ប្រជាជននៅក្នុងឃុំគោលដៅដែលបានស្ទង់មតិ តាមរូបភាពផ្សេងៗគ្នា។ បែបផែនធាតុអាកាសដែលមិនអាចទស្សន៍ទាយបាន នាំឱ្យមានការខ្វះខាតទឹកសម្រាប់កសិកម្ម ការបាត់បង់ជីវិតសត្វពាហនៈ ដោយសារគ្រោះរាំងស្ងួត និងការខូចខាតផ្ទះសម្បែងដោយសារគ្រោះទឹកជំនន់ ដែលធ្វើឱ្យផលផលិតធ្លាក់ចុះ និងការបាត់បង់ប្រាក់ចំណូល។ កសិករ ជាពិសេសអ្នកដាំដុះ

រូបភាពទី១៖ ប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុដែលអ្នកស្រុកបានជួបប្រទះក្នុងរយៈពេលដប់ឆ្នាំកន្លងមក តាមឃុំ (គិតជាភាគរយ)



រូបភាពទី២៖ កត្តាចម្បងនៃការធ្វើចំណាកស្រុកតាមឃុំ (គិតជាភាគរយ)




ជំឡុងមី ប្រឈមនឹងបញ្ហាធំ ដែលនាំឱ្យមានការដាំឡើងវិញ និងមិនចង់ដាំដុះដំណាំមួយចំនួន។ ទោះបីមានការព្យាយាមប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីក៏ដោយ ក៏នៅតែមានឧបសគ្គដូចជា ថ្លៃដើមផលិតខ្ពស់ និងបញ្ហាសុខភាព។ គ្រួសារនេសាទ ក៏ទទួលរងផលប៉ះពាល់ពីការថយចុះនៃបរិមាណត្រីដោយសារបឹងធម្មជាតិរាំងស្ងួត។ ការរកឃើញទាំងនេះឆ្លុះបញ្ចាំងពីនិន្នាការទូលំទូលាយនៅកម្ពុជា ដែលការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់ផលិតភាពកសិកម្ម និងជីវភាពរស់នៅតាមជនបទ ដោយសារការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាមានកម្រិត ការពឹងផ្អែកលើធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់។

តំបន់សិក្សានីមួយៗ ប្រឈមនឹងកម្រិតគ្រោះថ្នាក់អាកាសធាតុផ្សេងៗគ្នា រួមមាន សីតុណ្ហភាពខ្ពស់ ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះព្រៃ ការផ្ទុះនៃសត្វល្អិត ខ្យល់កន្ត្រាក់ និងរដូវកាលមិនប្រក្រតី (រូបភាពទី១)។ គួរកត់សម្គាល់ សីតុណ្ហភាពខ្ពស់ និងខ្យល់កន្ត្រាក់ គឺជាបញ្ហាធ្ងន់ធ្ងរបំផុត ដោយមានកម្រិតប៉ះពាល់ "មធ្យម" នៅទូទាំងតំបន់ទាំងអស់។ ផ្ទុយទៅវិញ គ្រោះរាំងស្ងួត និងការផ្ទុះនៃសត្វល្អិត បង្កការគំរាមកំហែងតិចជាង ចំណែកភ្លើងឆេះព្រៃ ត្រូវបានចាត់ទុកថា មានផលប៉ះពាល់ "ទាបបំផុត"។

តាមរយៈការសិក្សា ឃុំកញ្ជរ ជាពិសេសងាយរងគ្រោះដោយគ្រោះរាំងស្ងួត ដែលមានកម្រិតហានិភ័យខ្ពស់ ខណៈសីតុណ្ហភាពខ្ពស់ និងភ្លើងឆេះព្រៃ បង្កការគំរាមកំហែងមធ្យម និងទឹកជំនន់ មានហានិភ័យតិចជាងគេ។ នៅឃុំស្រែខ្ទុម ហានិភ័យកម្តៅសីតុណ្ហភាព គឺខ្ពស់គួរឱ្យព្រួយបារម្ភ ហើយខ្យល់កន្ត្រាក់ និងការផ្លាស់ប្តូររដូវកាល មានហានិភ័យមធ្យម ខណៈទឹកជំនន់ និងភ្លើងឆេះព្រៃ មិនជាការបារម្ភពេកទេ។ ឃុំក្បាលរមាស ប្រឈមនឹងហានិភ័យខ្លាំងទាំងសីតុណ្ហភាពខ្ពស់ និងខ្យល់កន្ត្រាក់ ដោយគ្រោះរាំងស្ងួតក៏បង្កការគំរាមកំហែងមធ្យមផងដែរ។ នៅទីនេះ ទឹកជំនន់ និងភ្លើងឆេះព្រៃ គឺជាហានិភ័យដែលកើតមានតិចជាង។

នៅឃុំស្រែខ្ទុម បញ្ហារវាងការកាប់បំផ្លាញព្រៃឈើ និងលំនាំអាកាសធាតុប្រែប្រួល គឺជាបញ្ហាធ្ងន់ធ្ងរ។ ការកើនឡើងសីតុណ្ហភាព និងការធ្លាក់ភ្លៀងមិនទៀងទាត់ ធ្វើឱ្យមានគ្រោះរាំងស្ងួត ដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ដំណាំ ដូចជាដំណាំជំឡុងមី។ ការរំខានដល់ការងារកសិកម្មបែបប្រពៃនេះបណ្តាលឱ្យមានការថយចុះគុណភាពដី និងបង្កបញ្ហាជីវភាពក្នុងវិស័យកសិកម្ម។

## ហេតុអ្វីបានជាប្រជាជនធ្វើចំណាកស្រុក៖ ការលំបាកផ្នែកសេដ្ឋកិច្ច និងផលប៉ះពាល់អាកាសធាតុ

ខណៈដែលមានកត្តាជាច្រើន ប៉ះពាល់ដល់ការធ្វើចំណាកស្រុក ការសិក្សាបានកំណត់ថា ភាពក្រីក្រ គឺជាកត្តាសេដ្ឋកិច្ចសំខាន់បំផុត ដែលជំរុញឱ្យមានការធ្វើចំណាកស្រុក ដោយអ្នកឆ្លើយតបពីការស្ទង់មតិជាង ៣០% បានលើកឡើងថា វាជាមូលហេតុចម្បង (រូបភាពទី២)។ បញ្ហានេះកាន់តែ

រូបភាពទី៣៖ ការគាំទ្រក្នុងសហគមន៍




រូបភាពទី៤៖ របៀបដោះស្រាយរបស់សហគមន៍មូលដ្ឋាន ទល់នឹងការខាតបង់ដោយអាកាសធាតុតាមឃុំ (គិតជាភាគរយ)




ធ្ងន់ធ្ងរឡើងដោយភាពខ្វះការងារ និងបំណុល ដែលបានធ្វើឱ្យស្ថានការណ៍កាន់តែលំបាក។

ការប្រែប្រួលអាកាសធាតុ ក៏ជាកត្តាមួយដែលមិនអាចមើលរំលងផងដែរ។ ទោះមិនមែនជាកត្តាសំខាន់បំផុតក៏ដោយ ក៏ផលប៉ះពាល់បានបង្ហាញយ៉ាងច្បាស់ ដោយសារមានអ្នកឆ្លើយសំណួរ ៥-៧% បានលើកឡើងថា ការថយចុះទិន្នផលដំណាំ ជាកត្តាមួយ ក្នុងការសម្រេចចិត្តធ្វើចំណាកស្រុក។ បន្ថែមពីនេះ មានអ្នកឆ្លើយសំណួរ ២-៣% បានលើកឡើងពីគ្រោះរាំងស្ងួត និងកង្វះទឹក និង ១-៣% បានលើកឡើងពីភ្លៀងធ្លាក់ខ្លាំង និងទឹកជំនន់ ជាកត្តាចូលរួម។

កត្តាសេដ្ឋកិច្ចរួមបញ្ចូលគ្នា ជាកត្តាដែលមានឥទ្ធិពលយ៉ាងខ្លាំងបំផុត ដោយបានរួមចំណែកប្រហែល ៥០-៦០% នៃមូលហេតុដែលជំរុញឱ្យមានការធ្វើចំណាកស្រុក។ បន្ទាប់មកកត្តាសង្គម និងវប្បធម៌ ក៏មានចំណែកប្រហែល ២៥-៣០% នៃមូលហេតុក្នុងការធ្វើចំណាកស្រុក។ កត្តាបរិស្ថាន ទោះបីជាមានផលប៉ះពាល់ក៏ពិតមែន តែវាមានឥទ្ធិពលតិចជាងកត្តាសេដ្ឋកិច្ច និងសង្គម ដោយរួមចំណែកប្រហែល ៤-៧% នៃការសម្រេចចិត្តធ្វើចំណាកស្រុក។

ជាសង្ខេប ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើជីវភាពរស់នៅ មិនអាចមើលរំលងបានទេ។ វាបានចូលរួមចំណែក ក្នុងការជំរុញឱ្យមានការធ្វើចំណាកស្រុក ដោយបង្កភាពលំបាកផ្នែកសេដ្ឋកិច្ច និងការបាត់បង់ទិន្នផលដំណាំ។ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល បានបញ្ជាក់ថា ការខ្វះការគាំទ្រផ្នែកកសិកម្ម ទិន្នផលទាប និងបំណុល បានជំរុញឱ្យបុគ្គលម្នាក់ៗ ស្វែងរកប្រាក់ចំណូលបន្ថែមទៀតពីកន្លែងផ្សេង។ ការខូចខាតដំណាំស្វាយចន្ទី និងកៅស៊ូ ដោយសារព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ បានបង្ខំឱ្យប្រជាជនជាច្រើន ធ្វើចំណាកស្រុករយៈពេលខ្លី ឬចំណាកស្រុកតាមរដូវ ដើម្បីជាមធ្យោបាយក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃ។ នេះបានសង្កត់ធ្ងន់ពីតម្រូវការគោលនយោបាយគ្រប់ជ្រុងជ្រោយ ដើម្បីដោះបញ្ហាចំណាកស្រុកដែលបណ្ដាលមកពីកត្តាសេដ្ឋកិច្ច និងបរិស្ថាន។

## *សមត្ថភាពបន្សាំ៖ យុទ្ធសាស្ត្រសហគមន៍ដោះស្រាយជាមួយបញ្ហាប្រែប្រួលអាកាសធាតុ*

ការប្រែប្រួលអាកាសធាតុ បានប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជន។ នៅក្នុងឃុំដែលបានសិក្សាមានគ្រួសារ ៦៧,១% បានរងផលប៉ះពាល់ដោយសារតែអាកាសធាតុធ្ងន់ធ្ងរ ដែលធ្វើឱ្យមានការបាត់បង់ទ្រព្យសម្បត្តិ ដំណាំ និងសត្វចិញ្ចឹម ព្រមទាំងមានការចំណាយខ្ពស់លើសុខាភិបាល។ ផលប៉ះពាល់ទាំងនោះរួមមាន ការថយចុះចំនួនការងារ និងការបិទដំណើរការអាជីវកម្ម។ គួរកត់សម្គាល់ថា គ្រោះរាំងស្ងួតបានកើតមានឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០២០ បានធ្វើឱ្យទិន្នផលដំណាំធ្លាក់ចុះជាខ្លាំង បណ្ដាលឱ្យជីវភាពរស់នៅរបស់ប្រជាកសិករ បានរងផលប៉ះពាល់គួរឱ្យកត់សម្គាល់។

ដើម្បីទប់ទល់នឹងផលប៉ះពាល់ទាំងនេះ កសិករត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស រួមទាំងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងការដឹកជញ្ជូនដែលល្អប្រសើរ។ អ្នកឆ្លើយតបការស្ទង់មតិ ក៏បានលើកឡើងអំពីយុទ្ធសាស្ត្រផ្សេងៗ ដើម្បីកាត់បន្ថយផលប៉ះពាល់អាកាសធាតុ រួមទាំងការធ្វើចំណាកស្រុក និងការខ្ចីប្រាក់។ ការចូលរួមសកម្មភាពសហគមន៍ គម្រោងដែលមានមូលនិធិ ដូចជា គម្រោងរេដបូក និងការបង្កើនការយល់ដឹងអំពី ការប្រែប្រួលអាកាសធាតុ ត្រូវបានលើកឡើងថា ជាកត្តាសំខាន់សម្រាប់ការលើកកម្ពស់ជីវភាព និងការអភិវឌ្ឍមូលដ្ឋាន។ ទោះជាយ៉ាងណា ប្រជាជននៅមិនទាន់ពេញចិត្តចំពោះការគាំទ្រដែលបានទទួល និងយុទ្ធសាស្ត្រឆ្លើយតបនៅមានកម្រិត។ បណ្ដាញសង្គមគឺជាមធ្យោបាយសំខាន់បំផុត ក្នុងការទទួលព័ត៌មានទាក់ទងនឹងអាកាសធាតុ ខណៈមិត្តភក្តិ និងសមាជិកគ្រួសារជាប្រភពព័ត៌មានទីពីរ។ ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និងកិច្ចប្រជុំសហគមន៍ ក៏បានចូលរួមក្នុងការលើកកម្ពស់ការយល់ដឹងអំពីអាកាសធាតុផងដែរ ខណៈព័ត៌មានពីអង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធប្រកាសអាសន្នមានកម្រិតទាប។ ការរកឃើញនេះបានសង្កត់ធ្ងន់ ពីសារៈសំខាន់នៃបណ្ដាញទំនាក់

ទំនងផ្សេងៗ ក្នុងការផ្ដល់ព័ត៌មានអំពីអាកាសធាតុ នៅកម្រិតមូលដ្ឋាន។

ការចូលរួមរបស់សហគមន៍ និងការដឹកនាំ ក៏ជាកត្តាសំខាន់ក្នុងការបង្កើនសមត្ថភាពបន្សាំផងដែរ។ ភាគច្រើននៃចំនួនប្រជាជនដែលបានសិក្សា បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពកែលម្អសហគមន៍ ដែលមានចំនួនលើសពី ៦៤% បានចូលរួមការជួបប្រជុំឃុំ។ គម្រោងដូចជា រេដបូក ដែលបានគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល គឺមានសារៈសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសហគមន៍ និងកាត់បន្ថយការធ្វើចំណាកស្រុក។ ទោះយ៉ាងណា ការទទួលយកតួនាទីជាអ្នកដឹកនាំក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត នៅតែមានកម្រិតចំពោះអ្នកចូលរួមភាគច្រើន។

ដោយឡែក ប្រព័ន្ធគាំទ្រ និងយុទ្ធសាស្ត្រឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺជាចំណុចដែលត្រូវយកចិត្តទុកដាក់។ ទស្សនៈទូទៅរបស់ប្រជាជន ការគាំទ្រនៅមិនទាន់មានគ្រប់គ្រាន់ (រូបភាពទី៣)។ យុទ្ធសាស្ត្រដែលត្រូវប្រើក្នុងការទប់ទល់នឹងការបាត់បង់ដោយអាកាសធាតុ រួមមាន ការខ្ចីប្រាក់ ការធ្វើចំណាកស្រុកដើម្បីការងារ និងការប្រើប្រាស់ប្រាក់សន្សំ (រូបភាពទី៤)។ គួរកត់សម្គាល់ ក្នុងតំបន់មួយចំនួន ប្រជាជននៅខ្វះយុទ្ធសាស្ត្រដោះស្រាយបញ្ហាច្បាស់លាស់ ហើយផែនការបង្កើនភាពធន់នឹងអាកាសធាតុមិនត្រូវបានបញ្ចូលទាំងស្រុងទៅក្នុងផែនការអភិវឌ្ឍភូមិ ទោះបីជាមានការគាំទ្រពីគម្រោងរេដបូក ក៏ដោយ។

## ការយល់ដឹងពីកិច្ចសន្ទនាគោលនយោបាយ៖ ការពង្រឹងការឆ្លើយតបនឹងការធ្វើចំណាកស្រុកដោយសារអាកាសធាតុ

ការពិភាក្សាគោលនយោបាយនៅថ្នាក់ក្រោមជាតិ បានលើកឡើងយុទ្ធសាស្ត្រមួយចំនួន ក្នុងការដោះស្រាយបញ្ហាការធ្វើចំណាកស្រុកដោយសារអាកាសធាតុ។ កម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈត្រូវបានសង្កត់ធ្ងន់ថា ជាកម្មវិធីដែលទទួលបានជោគជ័យជាងគេ ក្នុងការផ្ដល់ឱកាសការងារភ្លាមៗជាពិសេសនៅក្នុងតំបន់ឧស្សាហកម្មនៅទីរួមខេត្តក្រចេះ។ គំនិតផ្ដួចផ្ដើមកសិកម្មផ្ដោតលើ ការលើកកម្ពស់ការអនុវត្តប្រកបដោយភាពធន់នឹងអាកាសធាតុ និងការផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេសស្ដីពី កសិកម្មឆ្លាតវៃ នឹងជំរុញសេដ្ឋកិច្ចមូលដ្ឋាន និងពង្រឹងសន្តិសុខស្បៀង ដែលអាចកាត់បន្ថយការធ្វើចំណាកស្រុក។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានកត់សម្គាល់ថា បានធ្វើការលើកកម្ពស់ការត្រៀមខ្លួន និងវិធានការឆ្លើយតប ដែលបានជួយកាត់បន្ថយការផ្លាស់ទីលំនៅ។ ការកែទម្រង់សេវាសាធារណៈ និងប្រព័ន្ធគាំទ្រសង្គម រួមទាំងការធ្វើបច្ចុប្បន្នភាពគ្រួសារក្រីក្រ (IDPoor) និងការអនុវត្តគោលនយោបាយធានារ៉ាប់រងសង្គម បានកែលម្អការគាំពារសង្គមសម្រាប់ជនក្រីក្រ និងពង្រឹងភាពធន់របស់សហគមន៍។ វិធានការទាំងនេះ ត្រូវបានបញ្ចូលជាទៀងទាត់ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំរំកិលបីឆ្នាំ ដើម្បីធានាដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់នៃអាកាសធាតុ និងការគាំទ្រសហគមន៍ដែលរងផលប៉ះពាល់។

អាជ្ញាធរថ្នាក់ក្រោមជាតិ បានសង្កត់ធ្ងន់លើតម្រូវការសំខាន់នៃធនធានហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់កម្មវិធីជ្រើសរើសការងារ និងការបណ្ដុះបណ្ដាលបច្ចេកទេសដែលត្រូវការសម្រាប់កសិកម្មដែលធន់នឹងអាកាសធាតុ។ យុទ្ធសាស្ត្រសម្រាប់ការចូលរួមរបស់សហគមន៍ រួមទាំងការស្ទង់មតិវេទិកាសាធារណៈ និងការចូលរួមផ្ទាល់ ត្រូវបានកំណត់ថាជាកត្តាសំខាន់ក្នុងការធ្វើផែនការអភិវឌ្ឍន៍ ដែលសមស្របតាមចំណេះដឹងមូលដ្ឋាន និងតម្រូវការរបស់សហគមន៍ ដើម្បីកែលម្អភាពធន់នឹងអាកាសធាតុ។ លើសពីនេះ ការគាំទ្រប្រជាជនដែលងាយរងគ្រោះ តាមរយៈការបណ្ដុះបណ្ដាលការលើកកម្ពស់ការអនុវត្តការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព និងគំនិតផ្ដួចផ្ដើមសហគមន៍ដែលមានការចូលរួមពីជនក្រីក្រ ចាស់ជរា ជនពិការ និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ត្រូវបានសង្កត់ធ្ងន់ថាជាជំហានសំខាន់មួយសម្រាប់ការលើកកម្ពស់ប្រកបដោយបរិយាបន្ន។ ទោះបីជាមានការស្របគ្នា រវាងទ្រឹស្ដីជាមួយនឹងយុទ្ធសាស្ត្រផែនការជាតិ ការអនុវត្តជាក់ស្ដែងនៃវិធានការទាំងនេះ អាស្រ័យលើការធានាបាននូវហិរញ្ញប្បទានគ្រប់គ្រាន់ និងការដោះស្រាយទស្សនៈវប្បធម៌ក្នុងតំបន់ចំពោះការធ្វើចំណាកស្រុក។

## សេចក្ដីសន្និដ្ឋាន និងសំណើគោលនយោបាយ

ទំនាក់ទំនងរវាង ការផ្លាស់ប្ដូរអាកាសធាតុ និងការធ្វើចំណាកស្រុកនៅជនបទកម្ពុជា មានលក្ខណៈស្មុគស្មាញ។ វាពិតជាបានបង្ហាញថា ការកើនសីតុណ្ហភាព និងការផ្លាស់ប្ដូររដូវកាលលំបាកក្នុងការព្យាករណ៍ កំពុងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការសម្រេចចិត្តរបស់ប្រជាជននៅជនបទ ជាពិសេសពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក។ ផលប៉ះពាល់សេដ្ឋកិច្ចដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដូចជា ការបាត់បង់ចំណូលដោយសារដំណាំខូចខាត ដែលបណ្ដាលមកពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ កំពុងជំរុញឱ្យការធ្វើចំណាកស្រុកមានកើនឡើង។ នេះបានបង្ហាញពីភាពបន្ទាន់ក្នុងការដោះស្រាយបញ្ហាធ្វើចំណាកស្រុក ដោយសារអាកាសធាតុ ដែលជាបញ្ហាសង្គម-សេដ្ឋកិច្ចដ៏សំខាន់មួយ។ ដោយផ្អែកលើលទ្ធផលក្នុងការសិក្សានេះ វាជាការចាំបាច់ក្នុងការរៀបចំគោលនយោបាយ ដើម្បីពង្រឹងភាពធន់របស់សហគមន៍ជនបទដោយផ្ដោតលើសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទល់នឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការធ្វើចំណាកស្រុក។

អនុសាសន៍ដូចខាងក្រោមត្រូវបានស្នើឡើង៖

### នៅថ្នាក់ក្រោមជាតិ

- *ការបណ្តុះបណ្តាលខាងកសិកម្ម៖* អនុវត្តកម្មវិធីបណ្តុះបណ្តាលនៅថ្នាក់ភូមិ ដោយប្រើប្រាស់ចំណេះដឹងជនជាតិដើម និងធនធាននៅក្នុងមូលដ្ឋានមានស្រាប់ ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុក្នុងវិស័យកសិកម្ម។ ផ្តោតលើការផ្សព្វផ្សាយ បច្ចេកទេសកសិកម្មខ្នាតតូចប្រកបដោយភាពធន់នឹងអាកាសធាតុ ដែលផ្លាស់ប្តូរតាមតម្រូវការរបស់កសិករ និងសហគមន៍ ធានាដល់ការអនុវត្តជាក់ស្តែង និងភាពងាយស្រួល។ បញ្ចូលការអនុវត្តកសិកម្មឆ្លាតវៃ និងការអនុវត្តកសិកម្មដោយនិរន្តរភាព ដែលលើកកម្ពស់ដល់ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងការអភិរក្សដី និងទឹក ក្នុងរយៈពេលវែង។ លើសពីនេះ ពង្រឹងការបង្កើនចំណូលពេញមួយឆ្នាំ តាមរយៈការជំរុញផលិតភាពកសិកម្មដោយមានសេវាផ្សព្វផ្សាយកសិកម្ម ពីមន្ត្រីកសិកម្មឃុំ។ វិធីសាស្ត្រនេះ លើកកម្ពស់វិស័យកសិកម្ម និងប្រព័ន្ធអេកូឡូស៊ីរយៈពេលវែង។
- *ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ៖* ការផ្តួចផ្តើមគម្រោងអភិវឌ្ឍន៍ និងជួសជុលប្រព័ន្ធធារាសាស្ត្រ នៅក្នុងឃុំ និងស្រុក ដើម្បីពង្រឹងផលិតភាពកសិកម្មនៅក្នុងមូលដ្ឋាន និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ បង្កើនសមត្ថភាពគណៈកម្មាធិការគ្រប់គ្រងធនធានទឹក ដែលដំណើរការដោយសហគមន៍ ដើម្បីត្រួតពិនិត្យការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រទាំងនេះដោយនិរន្តរភាព។ លើសពីនេះ ផ្តោតលើការសាងសង់ស្ថានីយ៍បូមទឹកខ្នាតតូច និងមធ្យម ដែលប្រើប្រាស់បច្ចេកវិទ្យាបូមទឹក ដោយប្រើថាមពលពន្លឺព្រះអាទិត្យ។ នោះវានឹងបង្កើនប្រសិទ្ធភាពប្រព័ន្ធធារាសាស្ត្រ និងជំរុញការប្រើប្រាស់ទឹកដោយនិរន្តរភាព និងបានកាត់បន្ថយ ការពឹងផ្អែកលើប្រភពថាមពលប្រពៃណី ដើម្បីគាំទ្របន្ថែមទៀត ដល់ភាពធន់នឹងអាកាសធាតុ និងផលិតភាពក្នុងវិស័យកសិកម្ម។
- *ការចូលរួមរបស់សហគមន៍៖* ការសកម្មចូលរួមរបស់សមាជិកសហគមន៍ ទាំងក្នុងដំណាក់កាលធ្វើផែនការ និងការអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីបង្កើនភាពជាម្ចាស់កម្មសិទ្ធិ និងធានាបានតាមតម្រូវការរបស់មូលដ្ឋាន។ បង្កើតគណៈកម្មាធិការមូលដ្ឋាន ដោយមានអ្នកតំណាងសហគមន៍ផ្នែកផ្សេងៗ ដើម្បីត្រួតពិនិត្យ និងណែនាំយុទ្ធសាស្ត្របន្សាំ ធានាថាសហគមន៍អាចឆ្លើយតបនឹងបញ្ហាប្រឈម នៅក្នុងមូលដ្ឋានរបស់ពួកគេបាន។ លើសពីនេះទៀត បង្កើតទីផ្សារកសិកម្មនៅក្នុងមូលដ្ឋាន ដើម្បីគាំទ្រដល់ការលក់ និងចែកចាយផលិតផល ដែលមាននៅក្នុងមូលដ្ឋាន ហេតុនេះវាពង្រឹងសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន និងផ្តល់ឱកាសដល់កសិករ បានទំនាក់ទំនងជាមួយអ្នកទិញផ្ទាល់។
- *ការអភិវឌ្ឍជំនាញរបស់យុវជន៖* លើកទឹកចិត្តយុវជន ជាពិសេសអ្នកមកពីក្រុមងាយរងគ្រោះ ឱ្យមកចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET) ដើម្បីទទួលបានជំនាញនិងចំណេះដឹងដែលត្រូវការនៅក្នុងទីផ្សារការងារ។ កម្មវិធីនេះ មិនត្រឹមតែចូលរួមចំណែកដល់ការលូតលាស់របស់ពួកគាត់ផ្ទាល់នោះទេ ប៉ុន្តែក៏បានជួយដល់គោលបំណងទូទៅ ក្នុងការបង្កើតកម្លាំងពលកម្ម ដែលមានសមត្ថភាព ទប់ទល់នឹងបញ្ហាដែលកើតមានដោយសារការប្រែប្រួលអាកាសធាតុផងដែរ។ លើសពីនេះ ក៏ជំរុញការចូលរួមរបស់យុវជននៅមូលដ្ឋាន ដើម្បីផ្តួចផ្តើមគំនិតអភិវឌ្ឍន៍សហគមន៍ និងបង្កើតវេទិកា បណ្តាញយុវជនក្នុងការចែករំលែកអនុវត្តន៍ល្អ និងជំរុញឱ្យមានធនធានជំនាញនានា។

### នៅថ្នាក់ជាតិ

- *ការរៀបចំគោលនយោបាយ៖* បញ្ចូលការធ្វើចំណាកស្រុកដោយសារមានការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រ ដែលទាក់ទងនឹងការអភិវឌ្ឍជនបទ កសិកម្ម និងការងារ។ នៅក្នុងនេះមានរួមបញ្ចូលការយល់ដឹងអំពី របៀបគ្រប់គ្រងការធ្វើចំណាកស្រុក ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងរួមបញ្ចូលចំណេះដឹងនេះ ទៅក្នុងវិធានការដែលមានស្រាប់។ លើសពីនេះ ការរួមបញ្ចូលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើការធ្វើចំណាកស្រុក ទៅក្នុងរបាយការណ៍រួមចំណែករបស់ប្រទេសកម្ពុជា ក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តី ការប្រែប្រួលអាកាសធាតុ (NDC) និងផែនការសកម្មភាព។ ការដាក់អនុវត្ត គោលនយោបាយដែលលើកកម្ពស់ដល់ការអនុវត្តកសិកម្មដោយនិរន្តរភាព ដោយមានផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងការគាំទ្រដល់កសិករ ដើម្បីទទួលយកការអនុវត្តនេះ។
- *ការស្រាវជ្រាវ និងអភិវឌ្ឍន៍៖* វិនិយោគលើគម្រោងស្រាវជ្រាវ ដែលផ្តោតការយល់ដឹងអំពី ទំនាក់ទំនងដ៏ស្មុគស្មាញ រវាងបញ្ហាប្រែប្រួលអាកាសធាតុ និងលំនាំចំណាកស្រុក ដោយមានគោលបំណងអភិវឌ្ឍយុទ្ធសាស្ត្រការបន្សាំប្រកបដោយចីរភាព និងរយៈពេលវែង។ ចូលរួមជាដៃគូជាមួយអង្គការអន្តរជាតិ ដើម្បីទាញយកជំនាញជាសកល និងរកធនធានបន្ថែម សម្រាប់គម្រោងស្រាវជ្រាវ និងបន្សាំការប្រែប្រួលអាកាសធាតុ។ លើសពីនេះ គួរលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍ នៅក្នុងបច្ចេកវិទ្យាកសិកម្មជាក់លាក់។ នវានុវត្តន៍ទាំងនេះ អាចបង្កើន

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងជំរុញភាពធន់នឹងអាកាសធាតុ។ ក្នុងនេះអាចរួមមាន ការអភិវឌ្ឍដំណាំដែលធន់នឹងរាំងស្ងួត រួមផ្សំជាមួយបច្ចេកទេសជាក់លាក់ដែលអាចកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន។ ជាផ្នែកមួយនៃការប្រឹងប្រែងទាំងនេះ ការស្ទង់មតិ និងការចងក្រងជាឯកសារធនធានក្នុងស្រុក និងក្រៅស្រុក ពិតជាមានសារៈសំខាន់ ដែលអាចគាំទ្រដល់គម្រោងបន្សាំ និងកាត់បន្ថយផលប៉ះពាល់ ដោយសារការប្រែប្រួលអាកាសធាតុ ដើម្បីធានាឱ្យមានវិធានការលំអិត ក្នុងការដោះស្រាយបញ្ហាទាំងនេះ។

- *ការបង្កើនសមត្ថភាព*៖ ពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអង្គការសហគមន៍នានា ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោងបន្សាំនឹងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុតាមរយៈការបន្តបណ្តុះបណ្តាល និងការគាំទ្រជាបន្តបន្ទាប់។ ផ្តល់ជំនួយបច្ចេកទេស និងកម្មវិធីបណ្តុះបណ្តាលជាប្រព័ន្ធ ដើម្បីធានាដល់សមត្ថភាពបន្សាំរបស់មូលដ្ឋាន គឺស្របតាមយុទ្ធសាស្ត្រ និងគោលដៅអភិវឌ្ឍន៍ជាតិ។

## *ការណែនាំអនុវត្ត*

- កំណត់ច្បាស់លាស់អំពីតួនាទី និងកាតព្វកិច្ចរបស់ក្រសួងរដ្ឋាភិបាលនៅគ្រប់កម្រិត ដែលពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពគោលនយោបាយ ដើម្បីធានាភាពច្បាស់លាស់ និងការទទួលខុសត្រូវ។
- បង្កើតផែនការអនុវត្តលម្អិតជាជំហានៗ ដែលមានរួមបញ្ចូលកាលបរិច្ឆេទលម្អិត ការបែងចែកធនធាន និងការប្រើប្រាស់ថវិកា ដើម្បីជំរុញការអនុវត្តបានរលូនល្អ។
- រៀបចំកិច្ចសន្ទនា គោលនយោបាយ ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ ទាំងកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីពិភាក្សា កែលម្អ និងទទួលបានការឯកភាពសម្រាប់អនុសាសន៍ទាំងនេះ ព្រមទាំង ជំរុញកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍគោលនយោបាយ។

## ឯកសារយោង


ADB (Asian Development Bank). 2012. *Addressing climate change and migration in Asia and the Pacific*. Mandaluyong City, Philippines. https://www.adb.org/publications/addressing-climate-change-and-migration-asia-and-pacific.

Chhinh, Nyda, Serey Sok, Veasna Sou, and Pheakdey Nguonpha. 2023. "Roles of Agricultural Cooperatives (ACs) in Drought Risk Management among Smallholder Farmers in Pursat and Kampong Speu Provinces, Cambodia." *Water* 15(8): 1447. https://doi.org/10.3390/w15081447.

Docherty, Bonnie, and Tyler Giannini. 2009. "Confronting a rising tide: A proposal for a convention on climate change refugees." *Harvard Environmental Law Review* 33, 349–403.

IOM (International Organization for Migration). 2009. *Compendium of IOM's activities in migration, climate change and the environment*. Geneva: IOM. https://www.iom.int/sites/g/files/tmzbdl486/files/jahia/webdav/shared/shared/mainsite/activities/env_degradation/compendium_climate_change.pdf.

Leighton, Michelle. 2009. "Migration and slow-onset disasters: Desertification and drought." In *Migration, Environment and Climate Change: Assessing the Evidence*, edited by Frank Laczko and Christine Aghazarm, 321–351. Geneva: International Organization for Migration.

Mastrorillo, Marina, Rachel Licker, Pratikshya Bohra-Mishra, Giorgio Fagiolo, Lyndon D. Estes, and Michael Oppenheimer. 2016. "The influence of climate variability on internal migration flows in South Africa." *Global Environmental Change* 39, 155–169. https://doi.org/10.1016/j.gloenvcha.2016.04.014.

NIS (National Institute of Statistics). 2020. *General population census of the Kingdom of Cambodia 2019*. Phnom Penh, Cambodia https://www.nis.gov.kh/nis/Census2019/Final General Population Census 2019-English.pdf.

Sok, Serey, Nyda Chhinh, Sanara Hor, and Pheakday Nguonphan. 2021. "Climate change impacts on rice cultivation: a comparative study of the Tonle Sap and Mekong River." *Sustainability* 13 (16): 8979. https://doi.org/10.3390/su13168979.